សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ ក្រោមប្រធានបទ កាតព្វកិច្ចដែលព្រះសង្ឃនិងពុទ្ធបរិស័ទ ខ្មែររស់នៅបរទេសគប្បីអនុវត្ត ។

www.hoksavann.org

ថ្ងៃទី១ កញ្ញា ២០១១



ព្រះសង្ឃខ្មែរគ្រប់វត្តទាំងអស់ដែលរស់នៅបរទេស ក្រៅអំពីបំពេញកិច្ចកសាងវត្តផ្នែកសំណង់ គប្បីបំពេញកាតព្វកិច្ចមួយផ្នែកទៀត គឺការកសាងបញ្ញាស្មារតីរបស់ពុទ្ធបរិស័ទខ្មែរដោយព្រះធម៌នៃព្រះពុទ្ធជាម្ចាស់ឲ្យយល់តម្លៃព្រះពុទ្ធសាសនាកាន់តែច្បាស់លាស់ឡើង។ កិច្ចការនេះអាចអនុវត្តជននៅគ្រប់ឱកាសបុណ្យទានក្នុងព្រះពុទ្ធសាសនា ក្រៅពីកម្មវិធីសំដែងធម៌ទេសនា អាចឆ្លៀតពេលខ្លះទៀតពន្យល់ធម៌អាថ៌រយៈពេលវែងខ្លី យោលតាមពេលវេលាមុននឹងចាប់ផ្តើមសូត្រធម៌ ដែលជាពិធីកម្មរបស់ព្រះពុទ្ធសាសនា ។ គួរឲ្យសារៈសំខាន់ជាអាទិភាពទីមួយ គឺការពន្យល់ធម៌វិន័យដល់ពុទ្ធបរិស័ទ ឯការសូត្រធម៌ជាការសំខាន់ទីពីរ ។ តាមការសង្កេត ពុទ្ធបរិស័ទច្រើនពេញចិត្តនឹងការចំរើនព្រះបរិត្ត (សូត្រមន្ត) មិនសូវសួរគ្នាថា សូត្រមន្តឬមិនសូត្រទេ ច្រើនតែសួរគ្នាថា ទេសនាឬមិនទេសន៍ ។ សម័យពុទ្ធកាល សូម្បីមនុស្សតែម្នាក់ក៏ព្រះអង្គសំដែងប្រោសដែរ ឲ្យតែគេមានឧបនិស្ស័យគួរឲ្យព្រះអង្គប្រោសបាន ។ នៅក្នុងគម្ពីរសុត្តន្តបិដកផ្នែកព្រះសូត្របាននិយាយថា ពេលដែលព្រះពុទ្ធឬព្រះអរហន្តទាំងឡាយទទួលទេយ្យវត្ថុ មានសេនាសនៈ ឬចង្ហាន់ជាដើមពីពុទ្ធបរិស័ទ ព្រះអង្គបានធ្វើបត្តានុមោទនាដោយធម្មិកថាសំដែងធម៌ឲ្យពុទ្ធបរិស័ទយល់ចូលចិត្តនូវអំពើជាកុសលនោះ ។ ដូច្នេះបញ្ជាក់ថា សម័យពុទ្ធកាល ព្រះពុទ្ធនិងព្រះអរហន្តបានពន្យល់ធម៌ដល់ពុទ្ធបរិស័ទដែលប្រគេនទេយ្យវត្ថុ ពុំមែនសូត្រធម៌ទេ ការសូត្រធម៌ជូនពរកើតមានសម័យក្រោយមកទៀត ។ មួយទៀត ព្រះអរហន្តបានធ្វើបត្តានុមោទនាយ៉ាងខ្លីថា យំ យំ ឥច្ឆិតំ តំ តំ សមិជ្ឈតុ ប្រែថា សេចក្តីប្រាថ្នារបស់អ្នកយ៉ាងណា ចូរសំរេចយ៉ាងនោះចុះ ។ ត្រង់នេះបានសេចក្តីថា លោកសូមជូនពរឲ្យបានសំរេចតាមបំណងរបស់អ្នកបំពេញកុសល គឺលោកមិនអាចជួយអ្វីបាន ក្រៅពីអំពើល្អរបស់គេឡើយ ។ សម័យក្រោយមកមានជូនពរថា សូមឲ្យអស់លោកបានផលយ៉ាងនេះយ៉ាងនោះ គឺជារបបសុជីវធម៌ទំនាក់ទំនងល្អក្នុងសង្គម ។ ប៉ុន្តែមានការជូនពរខ្លះជាពាក្យប្រាប់មធ្យោបាយ ដូចពាក្យថា ពរ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ រមែងកើតមានដល់បុគ្គលដែលមានសេចក្តីគោរពកោតក្រែងដល់ចាស់ព្រឹទ្ធាចារ្យ ដល់អ្នកមានសីលជាដើម ។ គឺបើចង់បានពរ៤ប្រការនេះ ត្រូវតែប្រតិបត្តិតាមធម៌ខាងលើនេះ រួមជាមួយធម៌ដទៃទៀត មានការមិនសម្លាប់សត្វជាដើម ។ ពុទ្ធបរិស័ទអ្នកធ្វើបុណ្យមានការធ្វើទានជាដើមរមែងបានបុណ្យរួចហើយ ដោយចេតនាលះបង់របស់ខ្លួន ទោះបីព្រះសង្ឃមិនសូត្រធម៌ជូនពរ ក៏នៅតែបានបុណ្យដូចគ្នា ។ ការសូត្រធម៌ជូនពរនេះ ជារបបសុជីវធម៌ដើម្បីទំនាក់ទំនងល្អរវាងព្រះសង្ឃនិងពុទ្ធបរិស័ទ ។ ដូចជាជនណាម្នាក់ដែលបានទទួលអំណោយពីជនណាម្នាក់ តែងពោលពាក្យថាសូមអរគុណ ។ ពាក្យថាអរគុណ គឺការសំដែងអំណរចំពោះគុណ គឺសេចក្តីល្អដែលគេលះវត្ថុអ្វីមួយឲ្យដល់ខ្លួន ។ ដូច្នេះសូមកុំយល់ច្រឡំថា ធ្វើបុណ្យមានការធ្វើទានជាដើម បើព្រះសង្ឃមិនសូត្រធម៌ជូនពរទេមិនបានបុណ្យយ៉ាងនេះឡើយ ព្រោះបុណ្យកើតពីអ្នកធ្វើបុណ្យ ពុំមែនកើតពីអ្នកឲ្យឡើយ ។

សម័យបូរាណ ព្រះសង្ឃមានតួនាទីមួយទៀត គឺបង្រៀនអក្សរលេខនព្វន្តដល់កូនចៅខ្មែរប្រុសស្រី ។ ចំពោះកម្មវិធីសិក្សារបស់កូនចៅខ្មែរនៅបរទេស គេបង្រៀនទៅតាមកម្មវិធីរបស់ប្រទេសនីមួយៗ គ្មានកម្មវិធីរៀនអក្សរខ្មែរទេ ។ ដូច្នេះព្រះសង្ឃខ្មែរនៅបរទេសគួរបំពេញតួនាទីដូចសម័យបូរាណ គឺលៃពេលបង្រៀនអក្សរខ្មែរនិងអប់រំសីលធម៌ព្រះពុទ្ធសាសនាដល់កូនចៅខ្មែរនៅបរទេសឲ្យគ្រប់វត្ត ដើម្បីរក្សាវប្បធម៌ខ្មែរឲ្យបានគង់វង្ស ។ ការដឹកនាំកូនចៅឲ្យសិក្សាវប្បធម៌ជាតិនេះ ជាកាតព្វកិច្ចរបស់ឪពុកម្តាយនិងអាណាព្យាបាលខ្មែរនៅបរទេសដែលត្រូវបំពេញ ដោយធ្វើសហការជាមួយព្រះសង្ឃក្នុងការនាំកូនចៅមកវត្ត ដើម្បីឲ្យព្រះសង្ឃជួយបង្រៀននិងជួយអប់រំ ។ មានគ្រួសារអភិជនខ្មែរមួយដែលមករស់នៅបរទេស មុនប្រទេសកម្ពុជាធ្លាក់ទៅលើដៃខ្មែរក្រហម មិនត្រឹមតែមិនឲ្យកូនរៀនអក្សរខ្មែរប៉ុណ្ណោះទេ សូម្បីនៅផ្ទះមិនឲ្យកូននិយាយខ្មែរថែមទៀត ដោយយល់ថា បើឲ្យកូននិយាយខ្មែរខ្លាចរៀនភាសាបរទេសមិនទាន់គេ ។ ដល់ពេលកូនចេញធ្វើការនៅកន្លែងមួយ គេតំរូវឲ្យចេះនិយាយនិងសរសេរខ្មែរដើម្បីទាក់ទងសហគមន៍ខ្មែរ ទើបនឹកស្តាយក្រោយដែលកូនជាជនជាតិខ្មែរមិនចេះខ្មែរ ពុំអាចធ្វើការកន្លែងនោះបាន ។ គ្រួសារមួយទៀត មានទំនងដូចជាពេលកូនបានធ្វើជាវេជ្ជបណ្ឌិត មិនអាចនិយាយភាសាខ្មែរនៅពេលដែលពលរដ្ឋខ្មែរទៅពិគ្រោះជម្ងឺនៅក្នុងក្លីនិករបស់ខ្លួន ។ ចាប់ពីពេលដឹងថា វេជ្ជបណ្ឌិតនេះជាខ្មែរមិនចេះនិយាយខ្មែរ ទើបពលរដ្ឋខ្មែរភាគច្រើនឈប់ទៅក្លីនិករបស់គាត់ទៀត ព្រោះខ្មែរដែលចង់ទៅក្លីនិកខ្មែរដោយភាសាដូចគ្នាស្រណុកប្រាប់ពីជម្ងឺ ។ បើខ្មែរមិនចេះខ្មែរដដែល ក៏សំរេចចិត្តទៅពិគ្រោះជម្ងឺជាមួយវេជ្ជបណ្ឌិតជាតិដទៃដែលនៅជិតៗផ្ទះខ្លួនវិញ ។ ដោយបាត់ភ្ញៀវខាងខ្មែរដែលជាជាតិរបស់ខ្លួន ទើបនឹកស្តាយក្រោយ ដោយមិនបានហាត់និយាយនិងរៀនអក្សរខ្មែរ ។ ពលរដ្ឋខ្មែរដទៃទៀត គួរចាប់អារម្មណ៍អំពីបញ្ហានេះ បើទោះបីមិនយកភាសាខ្មែរធ្វើជាវិជ្ជាជីវៈក៏ដោយ ក៏មិនគួរបំបាត់ភាសាកំណើតរបស់ខ្លួនឡើយ (ភាសារលត់ ជាតិរលាយ) ។

ពុទ្ធបរិស័ទគួរកាត់អង្សាក់ឲ្យក្រាស់ប្រគេនព្រះសង្ឃពាក់រដូវរងារ ប្រសើរជាងប្រគេនអាវឲ្យព្រះសង្ឃពាក់ ដែលមិនល្អមើលចំពោះព្រះសង្ឃខ្មែរដែលជាព្រះសង្ឃថេរវាទ ។ សព្វថ្ងៃនេះ មិនឃើញពុទ្ធបរិស័ទប្រគេនបារីព្រះសង្ឃឡើយ សូម

រក្សាការមិនប្រគេននេះតទៅទៀត ព្រោះបារីតាមអ្នកស្រាវជ្រាវសង្កេតឃើញថា មានជាតិពុលចំនួន៥០០០មុខ ។ ការប្រគេនបារីព្រះសង្ឃមិនបានបុណ្យឡើយ តែត្រូវបានបាបទៅវិញ ព្រោះប្រគេនបារីដែលជាគ្រឿងពុលដល់លោក ។ ពេលព្រះសង្ឃកំពុងឆាន់ ពុទ្ធបរិស័ទមិនគួរនាំព្រះសង្ឃឲ្យមានពុទ្ធដីកាអំពីរឿងអ្វីឡើយ បើមានការអ្វីរង់ចាំព្រះសង្ឃឆាន់រួចសិន វៀរលែងតែការចាំបាច់អាចនិយាយបានខ្លះ ព្រោះពេលឆាន់ព្រះសង្ឃពិចារណានូវបច្ចវេក្ខញ្ញាណដែលហៅក្លាយមកថា ពិចារណាអជ្ជៈ អំពីផលប្រយោជន៍នៃចង្ហាន់ កុំឲ្យជាប់ចិត្តក្នុងរសនៃអាហារចំណី ។ ពេលបុណ្យទាន មិនគួរនាំគ្នាអុជធូបនៅក្នុងព្រះវិហារ ក្នុងឧបដ្ឋានសាលា ក្នុងកុដិឡើយ ព្រោះផ្សែងធូបក៏មានជាតិពុល ហើយនាំឲ្យខ្មៅកន្លែងដែលអុជនោះ បើជៀសវាងមិនទាន់បាន គួរអុជនៅខាងក្រៅ ។ គួរប្រើទៀននិងផ្កាវិញក្នុងការធ្វើសក្ការៈបូជា ព្រោះមិនមានជាតិពុល ។ របៀបប្រគេនត្រូវអនុវត្តតាមអង្គប្រាំយ៉ាងគឺ ១- របស់ដែលត្រូវប្រគេននោះ មិនធ្ងន់ មិនធំហួសពេក ល្មមមនុស្សយ៉ាងមធ្យមលើកម្នាក់ឯងបាន, ២- អ្នកប្រគេនចូលមកក្នុងហត្ថបាស គឺឃ្លាត២ហត្ថ១ចំអាមចូលមក, ៣- ទាយកបង្អោនទេយ្យវត្ថុចូលមក, ៤- ទាយកប្រគេនផ្ទាល់នឹងកាយ, ៥- ភិក្ខុទទួលផ្ទាល់នឹងកាយ ឬដោយរបស់ជាប់នឹងកាយ ។ ពុទ្ធបរិស័ទគួរនាំគ្នាឆ្លៀតពេលអានសៀវភៅធម៌ ឧស្សាហ៍ស្តាប់ធម៌ទេសនា ហើយយកមកពន្យល់កូនចៅផង ធ្វើដូច្នេះទើបព្រះពុទ្ធសាសនាចំរើនរុងរឿងនៅក្នុងប្រទេសនិងក្រៅប្រទេសខ្មែរបន្តមកកូនចៅជំនាន់ក្រោយៗមកទៀត ។៚

*　　　　*

*